ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍
BUDDHISM FOR DEVELOPMENT
អាស័យដ្ឋានៈ ផ្លូវជាតិលេខ ៥៧ ភូមិដីក្រហម សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន
ទូរស័ព្ទលេខៈ០១២ ៥៩៩ ៦៧៩ E-mail: bfdpln@bfdkhmer.org

---------------------

# របាយការណ៍ ខែ កញ្ញា ឆ្នាំ ២០១៥
## កម្មវិធីៈ អាហារូបករណ៍ EDM
## ប៉ៃលិនៈ ០០៧- ៤៤

## I-ព្រឹត្តការណ៍ជុំវិញ

<u>សេចក្តីផ្តើម</u>

**ក/ប្រវត្តិពដអៈ** ព.ដ.អ. ត្រូវបានបង្កើតឡើងនៅ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៩០ នៅវត្តប្រសាទសិរី ជំរំសាយធូឬទ្ធិសែន ដោយភិក្ខុ **ហេង មណីចិន្តា** និង ព្រះសង្ឃមួយក្រុម ដែលបានសិក្សា ឃើញនូវគុណតំលៃ របស់ពុទ្ធសាសនាក្នុងការជួយៈ

-ស្តារសន្តិភាព និង ការរួមរស់ជាមួយគ្នាឡើងវិញជាប្រជាជាតិខ្មែរ
-អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច សង្គម
-អភិវឌ្ឍន៍ចិត្តវិញ្ញាណ សតិបញ្ញា
-ស្តារសិទ្ធិមនុស្ស និង កសាងលទ្ធិប្រជាធិបតេយ្យ
-ពង្រីកតុល្យភាពរវាង បុគ្គល សង្គម និង ធម្មជាតិ អោយបានស្មើ នឹង ចីរកាល

**ខ/ភារកិច្ចៈ** ជួយអោយមានការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពដល់ប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជាតាមរយៈ ការអប់រំ ការផ្តល់យោបល់ និងការធ្វើគំរោកម្មវិធីនានាដែលមានការចូលរួមពីប្រជាពលរដ្ឋដោយផ្ទាល់។

**គ/ទស្សនវិស័យៈ** ចង់ឃើញនូវសង្គមប្រជាធិបតេយ្យមានការសិក្សាល្អមួយ ដែលគ្មានភាពក្រីក្រ គ្មានជំងឺដែលអាចការពារបាន មានការគោរពច្បាប់ គោរពសិទ្ធិមនុស្ស និងការពារ បរិស្ថានបានល្អ និងជាសង្គមសីលធម៌មួយដែលបដិបត្តិតាមឱវាទព្រះពុទ្ធសាសនា និងគោរពវប្បធម៌ប្រពៃណីខ្មែរ ព្រមជាមួយនិងការប្រុងប្រយត្ន័ចំពោះការគំរាមគំហែង និងឱកាស ( កាលានុវត្តភាព ) របស់សកលភាវូបនីយកម្ម ។

**ឃ/ទស្សនវិជ្ជាៈ** គំរោងដែលប្រកបដោយការចូលរួមរបស់ ព.ដ.អត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ របស់ក្រុមគោលដៅ និងដើម្បីសំរេចបាននូវ រម្យនីយភាពរវាងបច្ចេកបុគ្គល សង្គម និងបរិស្ថាន និងផ្តោតទៅលើការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គម ចិត្តវិញ្ញាណ និងសតិបញ្ញា របស់ក្រុមគោលដៅដោយមានព្រះធម៌ជាមគ្គុទ្ទេសក៍ក្នុងការណែនាំអោយឆ្ពោះទៅរកការពឹងពាក់ដោយខ្លួនឯងបានជាជំហានៗ ។

## II-ទិសដៅ និងគោលបំណង

១.<u>ទិសដៅគំរោងៈ</u> ជួយឧបត្ថម្ភកុមារក្រីក្រចំនួន ៨០ នាក់ / ស្រី ៥៣នាក់ ដែលស្ថិតគ្រួសារក្រីក្រដែលមិនមានលទ្ធភាពបញ្ជូនកូនអោយទៅសាលាបាន ។ កម្មវិធីនេះ អនុវត្តនៅក្នុង ០១ក្រុង និង០១ស្រុក ក្នុងខេត្តប៉ៃលិន ដើម្បីជួយកុមារទាំងនោះអោយមានឱកាសទៅសាលារៀន និងចាប់យកចំណេះដឹងសម្រាប់អនាគតរបស់ពួកគេ ។

## ២.គោលបំណង

**គោលបំណងទី១៖** ផ្តល់ការគាំទ្រផ្នែកសម្ភារៈ ថវិកា និងសីលធម៌ ដល់កុមារ **២២**នាក់ រៀននៅ សាលាបឋមសិក្សា កុមារ**២២** នាក់ រៀននៅអនុវិទ្យាល័យ, កុមារ **២៣**នាក់រៀននៅវិទ្យាល័យ, រៀននៅមហាវិទ្យាល័យ **១១**នាក់ និងជំនាញវិជ្ជាជីវៈចំនួន **០២** នាក់ អោយពួកគេបានទៅសាលា និងមិនបោះបង់ការសិក្សារបស់ពួកគេ ។

## III - ស្ថិតិកុមារ៖

### ក.តាម ឃុំ /សង្កាត់ ៖

| ខេត្តប៉ៃលិន | ឃុំ/សង្កាត់ | កុមារា | កុមារី | សរុប |
|---|---|---|---|---|
| ស្រុកសាលាក្រៅ | ស្ទឹងកាច់ | ០ | ១៤ | ១៤ |
| | អូរអណ្តូង | ០ | ០ | ០ |
| | សាលាក្រៅ | ២ | ១ | ៣ |
| | ស្ទឹងត្រង់ | ០ | ១ | ១ |
| សរុប | ៤ | ២ | ១៦ | ១៨ |
| ក្រុងប៉ៃលិន | អូរតាវ៉ៅ | ៣ | ៥ | ៨ |
| | ប៉ៃលិន | ៦ | ០៩ | ១៥ |
| | ទួលល្វា | ១៣ | ១៦ | ២៩ |
| | បរយ៉ាខា | ៣ | ៧ | ១០ |
| សរុប | ៤ | ២៥ | ៣៧ | ៦២ |
| **សរុបរួម** | **៨** | **២៧** | **៥៣** | **៨០** |

### ខ.ស្ថិតិកុមារតាមកម្រិតថ្នាក់ ៖

| Level | Nb. Girls | Nb. Boys | Total | Others |
|---|---|---|---|---|
| Grade 3 | 0 | 0 | **0** | |
| Grade 4 | 2 | 1 | **3** | |
| Grade 5 | 6 | 0 | **6** | |
| Grade 6 | 9 | 5 | **14** | |
| Grade 7 | 11 | 1 | **12** | |
| Grade 8 | 3 | 1 | **6** | |
| Grade 9 | 2 | 2 | **4** | |
| Grade 10 | 3 | 1 | **4** | |
| Grade 11 | 5 | 3 | **8** | |
| Grade 12 | 3 | 6 | **9** | |
| Exam 12 | 1 | 1 | **2** | |
| Professional Training | 1 | 2 | **3** | |
| University | 7 | 4 | **11** | |
| **TOTAL :** | **53** | **27** | **80** | |

-ក្នុងខែ  កញ្ញា  ឆ្នាំ២០១៥  បុគ្គលិកកម្មវិធីបានប្រឹក្សាយោបល់ជាមួយអាណាព្យាបាល  និងក្រុមគ្រួសារកុមារទាក់ទងនឹងការរកប្រាក់ចំណូលក្នុងគ្រួសារ ហើយសកម្មភាពនេះដំណើការរលូន។ ក្នុងនោះដោយគ្រួសារកុមារនីមួយៗ នៅបន្តសកម្មភាពដូចជា លក់ចាបហួយបន្តិចបន្តួចចិញ្ចឹមមាន់ ទា ជ្រូក  ដាំបន្លែតាមគ្រួសារ និងបណ្តុះកូនឈើហូបផ្លែ ។

-ក្នុងខែ កញ្ញា ឆ្នាំ២០១៥  បានប្រជុំជាមួយកូនចិញ្ចឹម តាមក្រុមដើម្បីអប់រំសីលធម៌ និងអនាម័យទូទៅបង្រៀនធម៌នមស្ការព្រះរតនត្រ័យ  ផ្សព្វផ្សាយច្បាប់នានា ជាពិសស ច្បាប់ចរាចរណ៍,ច្បាប់គ្រឿងញៀន,ជំរុញកុមារអោយខិតខំរៀនសូត្រ និងសរសេរសំបុត្រផ្ញើទៅឪពុកម្តាយធម៌  បានចំនួន **៣** លើក សរុបអ្នកចូលរួម**៧៨**នាក់ ស្រី **៥១** នាក់។

-ចុះសួរសុខទុក្ខតាមគ្រួសារ អោយកូនចិញ្ចឹមអនាម័យខ្លួនប្រាន ដេកក្នុងមុង  ជុំវិញផ្ទះសំបែង និងណែនាំអោយសរសេរសំបុត្រ  ផ្ញើទៅឪពុកម្តាយធម៌បានចំនួន០៨ លើក ។

-សំបុត្រកូនសរសេរផ្ញើទៅឪពុកម្តាយធម៌សំរាប់ ខែ កញ្ញាឆ្នាំ ២០១៥ បានចំនួន **0៦** សំបុត្រ។

-សំបុត្រឪពុកម្តាយធម៌ផ្ញើមកកូន សំរាប់ខែ កញ្ញា ឆ្នាំ២០១៥  បានចំនួន **00** សំបុត្រ។

-កុមារចិញ្ចឹមប្រលងមធ្យមសិក្សាទុតិយភូមិចំនួន ០៨ នាក់ស្រី ៤ នាក់ ប្រលងជាប់ ៤នាក់ ស្រី ២ នាក់ ។

-ខែ  កញ្ញា ឆ្នាំ២០១៥   បញ្ឈប់ការជួយឧត្ថម្ភ កុមារចំនួន០៣ នាក់ មូលហេតុ មានការងារធ្វើ ១ នាក់ និងផ្លាស់ប្តូរទីលំនៅ ០២ នាក់ ។

-សំរាប់ខែ  កញ្ញា ឆ្នាំ២០១៥ ឪពុកម្តាយធម៌ផ្តល់ប្រាក់ឧត្ថម្ភពិសេសចំនួន **០១** លើក កុមារចិញ្ចឹមចំនួន **០៥** នាក់ ប្រាក់ចំនួន **៤៣0.00$** ។ (មានតារាងជូនភ្ជាប់)

IV-**<u>សកម្មភាពផ្សេងៗ ៖</u>**

-ចូលរួមកិច្ចប្រជុំសាមញ្ញអាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្តប៉ៃលិន ចំនួន ១ លើក ។

-ចូលរួមកិច្ចប្រជុំសាមញ្ញអាណត្តិទី២ របស់ក្រុមប្រឹក្សាក្រុងប៉ៃលិន ចំនួន១ លើក ។

-ចូលរួមកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការ ពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ ខេត្តប៉ៃលិន១ លើក ។

-ចូលរួមកិច្ចប្រជុំសាមញ្ញ របស់គណៈកម្មាធិការ ពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ ក្រុងប៉ៃលិន ១លើក ។

V- **<u>ការលំបាក និង បញ្ហាដែលជួបប្រទះ ៖</u>**

-មធ្យោបាយធ្វើសកម្មភាពចាស់ទ្រុឌទ្រោម ខូចច្រើន ។

-ក្មេងបោះបង់កាសិក្សា ដោយកត្តាជីវភាពគ្រួសារ ចំណាកស្រុក ដោយសំភារៈនិយមអូសទាញដូចជា (ម៉ូតូ ទូរសព្ទ័...........................) ។

-ផ្ទះកុមារនៅឆ្ងាយពីសាលារៀន ( អវត្តមានច្រើន ) ។

VI- **<u>ដំណោះស្រាយដែលបានអនុវត្ត</u>**

-ពន្យល់លើកទឹកចិត្តដល់កូនចិញ្ចឹម និងអាណាព្យាបាល ឪពុកម្តាយ អោយស្គាល់អំពីគុណតម្លៃនៃការសិក្សា ។

- ជំរុញលើកទឹកចិត្ត ចំពោះកូនចិញ្ចឹមដែលរៀនខ្សោយ មានអាយុច្រើន អោយចូលរៀនបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជា ជួសជុល ម៉ូតូ ឡាន អ៊ុតសក់ កែសម្ផស្ស ......................។

VII- **<u>សំណូមពរ</u>**

-សុំម៉ូតូថ្មី ១ គ្រឿង ។

-សុំ កុំព្យូទ័រថ្មី + ម៉ាស៊ីនព្រីនថ្មី មួយឈុត ។

-ប្រាក់ឧបត្ថម អោយបានទាន់ពេលវេលា ។

VIII-**ផែនការបន្ត**

-តាមដានសុខភាពកុមារ  និងការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ។

-ប្រឹក្សាយោបល់ ជាមួយអាណាព្យាបាល និងគ្រួសារកុមារ ពីវិធីរកប្រាក់ចំណូលក្នុងគ្រួសារ ។

-ប្រជុំប្រចាំខែជាមួយកុមារចិញ្ចឹម និងអប់រំសីលធម៌ សិទ្ធិមនុស្ស គ្រឿងញៀនផ្សព្វផ្សាយគោលនយោបាយការពារកុមារ  និងច្បាប់នានា ........

-ទំនាក់ទំនងជាមួយឪពុកម្តាយធម៌ ផ្តល់ និងប្រមូលសំបុត្រ ។

ប៉ៃលិន,ថ្ងៃទី ២៣ ខែ កញ្ញា  ឆ្នាំ ២០១៥

អ្នកធ្វើរបាយការណ៍

ប៉ែន  អ៊ិយ

បានពិនិត្យដោយ

ប្រធានសាខា

**ឈាប ពោល**

# ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍

**BUDDHISM FOR DEVELOPMENT**

អាស័យដ្ឋានៈ ផ្លូវជាតិលេខ៥៧ភូមិដីក្រហម សង្កាត់អូរតាវៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន

ទូរស័ព្ទលេខៈ០១២ ៥៩៩ ៦៧៩ E-mail: bfdpln@bfdkhmer.org


----------------------

## ឈ្មោះកូនចិញ្ចឹមដែលទទួលបានឧបត្ថម្ភពិសេសពីឪពុកម្ដាយធម៌
## ប្រចាំខែ (កក្កដា-សីហា)ឆ្នាំ ២០១៥

| ល.រ | ឈ្មោះកុមារ | ភេទ | ថ្នាក់ទី | ចំនួនប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ម៉ុត លី | ស | រៀនពេទ្យឆ្នាំទី ៣ | ១០០.00 $ | សំរាប់ចំណាយថ្លៃរៀន |
| ២ | ឆេង មិថុនា | ស | រៀនពេទ្យឆ្នាំទី ៣ | ១០០.00 $ | សំរាប់ចំណាយថ្លៃរៀន |
| ៣ | ជិន ចាន់ធា | ស | ឆ្នាំទី៣ | ១៨០.00 $ | សំរាប់ចំណាយថ្លៃរៀន |
| ៤ | សូ បូរី | ប | ឆ្នាំទី ៤ | ២៥.00 $ | សំរាប់ចំណាយថ្លៃរៀន |
| | ម៉ក់ លីណា | ស | ៨ | ២៥.00 $ | សំរាប់ខួបកំណើត |
| សរុប | | | | ៤៣០.00$ | |

ប៉ៃលិន,ថ្ងៃទី ២៣ ខែ កញ្ញ ឆ្នាំ ២០១៥

អ្នកធ្វើតារាង

ប៉ែន អ៊ិយ